# ការចាក់វ៉ាក់សាំង HPV និង HPV៖ អ្វីដែលមាតាបិតាគ្រប់រូបគួរតែដឹង

## តើ HPV ជាអ្វី?

មេរោគ HPV (Human papillomavirus) គឺជាវីរុសដ៏សាមញ្ញបំផុតដែលមនុស្ស 8 នាក់ក្នុងចំណោម 10 នាក់នឹងមាននៅចំណុចណាមួយនៅក្នុងជីវិតរបស់ពួកគេ។ ការឆ្លងវីរុស HPV មួយចំនួនអាចដឹកនាំទៅរកជំងឺមហារីកនៅដំណាក់កាលបន្ទាប់ក្នុងជីវិត។



**គេបានប៉ានប្រមាណថាវីរុស HPV បង្កឲ្យមានករណីនៃជំងឺមហារីកចំនួន 37,000 ករណីនៅក្នុងមនុស្សប្រុសនិងមនុស្សស្រីជារៀងរាល់ឆ្នាំនៅសហរដ្ឋអាមេរិក ដែលនោះជាចំនួនស្មើគ្នាទៅនឹង ចំនួនអ្នកចូលរួមជាមធ្យមសម្រាប់កីឡាវាយកូនបាល់ក្នុងលីកកំពូលមួយផងដែរ។**

មានតែមហារីកក៏ស្បូនប៉ុណ្ណោះ ដែលជាជំងឺមហារីកមួយដែលបង្កដោយវីរុស HPV អាចត្រូវបានគេរកឃើញនៅដំណាក់កាលដំបូងជាមួយនឹងតេស្ត Pap។ ជំងឺមហារីកដទៃទៀតដែលបង្កឡើងដោយ HPV (ដូចជាជំងឺមហារីកបំពង់ក ប្រដាប់ភេទ ឬរន្ធគូថ) មិនអាចរកឃើញនោះទេរហូតទាល់តែជំងឺទាំងនោះមានសភាពធ្ងន់ធ្ងរកាន់តែខ្លាំង។ ការចាក់វ៉ាក់សាំង HPV ការពារការឆ្លងមេរោគដែលបណ្តាលឱ្យមានជំងឺមហារីកទាំងនេះ។

## តើខ្ញុំអាចការពារកូនរបស់ខ្ញុំពីវីរុស HPV ដោយរបៀបណា?

ការចាក់វ៉ាក់សាំង HPV អាចការពារជំងឺមហារីកជាង 90% ដែលបណ្តាលមកពីវីរុស HPV។ វ៉ាក់សាំង HPV មានសុវត្ថិភាពខ្លាំង ហើយការស្រាវជ្រាវបែបវិទ្យាសាស្រ្តបង្ហាញឲ្យឃើញថា អត្ថប្រយោជន៍មកពីការចាក់វ៉ាក់សាំង HPV មានច្រើនជាងហានិភ័យដែលអាចកើតមាន។ ដូសវ៉ាក់សាំងជាង 135 លានដូសត្រូវបានផ្តល់ជូននៅក្នុងសហរដ្ឋអាមេរិកតាំងពីឆ្នាំ 2006 ដូច្នេះហើយវ៉ាក់សាំង HPV មានកំណត់ត្រាសុវត្ថិភាពដ៏យូរអង្វែងដែលគាំទ្រដោយការអង្កេតតាមដានជាង 15 ឆ្នាំ។ ផលរំខានជាទូទៅមានលក្ខណៈតិចតួច ហើយធូរស្បើយឡើងវិញក្នុងរយៈពេលមួយឬពីរថ្ងៃ។ ទាំងនេះរួមបញ្ចូលទាំងការឈឺចាប់ កន្ទួលក្រហម ឬការហើមនៅកន្លែងដែលការចាក់ថ្នាំបង្ការដែលស្រដៀងគ្នាទៅនឹងវ៉ាក់សាំងផ្សេងទៀតដែរ។

**88%**

**ការថយចុះជំងឺឆ្លង HPV ក្នុងចំណោមក្មេងស្រីជំទង់**

**ការចាក់វ៉ាក់សាំង HPV ដំណើរការបានយ៉ាងល្អប្រសើរជាខ្លាំង។ ចាប់តាំងពីការចាក់វ៉ាក់សាំង HPV ត្រូវបានណែនាំជាលើកដំបូងក្នុងឆ្នាំ 2006 មក ការឆ្លងវីរុសប្រភេទ HPV ដែលបណ្តាលឱ្យមានជំងឺមហារីក HPV ភាគច្រើនបានធ្លាក់ចុះ 88% ក្នុងចំណោមក្មេងស្រីជំទង់និង 81% ក្នុងចំណោមស្ត្រីវ័យក្មេងពេញវ័យ។**

# ការចាក់វ៉ាក់សាំង HPV និង HPV៖ អ្វីដែលមាតាបិតាគ្រប់រូបគួរតែដឹង

ការចាក់វ៉ាក់សាំងប្រឆាំងនឹងមេរោគ HPV ត្រូវបានណែនាំដោយគណៈកម្មាធិការប្រឹក្សាយោបល់សហព័ន្ធស្តីពីការអនុវត្តការចាក់ថ្នាំបង្ការ (Advisory Committee on Immunization Practices) បណ្ឌិតសភាអាមេរិកផ្នែកជំងឺកុមារ (American Academy of Pediatrics) និងបណ្ឌិតសភាអាមេរិកផ្នែកគ្រូពេទ្យគ្រួសារ (American Academy of Family Physicians)។ វាក៏ត្រូវបានណែនាំផងដែរដោយសមាគមជំងឺមហារីកអាមេរិក និងច្បាប់បង្ការជំងឺមហារីក (Cancer Prevention Act) របស់រដ្ឋ California។

## តើនរណាគួរចាក់វ៉ាក់សាំង ហើយពេលណាពួកគេគួរចាក់វា?



**ដោយសារវ៉ាក់សាំងមានប្រសិទ្ធភាពជាងនៅពេលចាក់ក្នុងវ័យក្មេង វ៉ាក់សាំង HPV ពីរដូសត្រូវបានណែនាំសម្រាប់កុមារទាំងអស់ដែលមានអាយុពី 9 ទៅ 12 ឆ្នាំ ហើយដូសទីពីរគួរតែផ្តល់ជូនមុនពេលចាប់ផ្តើមថ្នាក់ទី 8។**

(កុមារដែលរង់ចាំរហូតដល់ពេលក្រោយដើម្បីទទួលបានដូសវ៉ាក់សាំង HPV ដំបូងរបស់គេអាចនឹងត្រូវការបីដូស។) វ៉ាក់សាំង HPV ជាញឹកញាប់ត្រូវបានផ្តល់ជូននៅក្នុងពេលតែមួយដូចនឹងវ៉ាក់សាំងសម្រាប់មនុស្សវ័យជំទង់ផ្សេងទៀតផងដែរដូចជាវ៉ាក់សាំង Tdap ដើម្បីបង្ការការក្អកខ្លាំង និងវ៉ាក់សាំងបង្ការជំងឺពីបាក់តេរីមេណាំងហ្គោកូក ដើម្បីបង្ការរោគរលាកស្រោមខួរក្បាលដោយសារបាក់តេរី។

## តើខ្ញុំអាចទទួលបានវ៉ាក់សាំង HPV សម្រាប់កូនរបស់ខ្ញុំនៅឯណា?

សូមសួរអ្នកផ្តល់សេវាថែទាំសុខភាព ឱសថការី ឬក្រសួងសុខាភិបាលក្នុងតំបន់របស់អ្នក ដើម្បីស្វែងយល់បន្ថែមអំពីវ៉ាក់សាំង HPV និងកន្លែងដែលអ្នកអាចទទួលបានវា។ វ៉ាក់សាំងនេះត្រូវបានរ៉ាប់រងដោយគម្រោងធានារ៉ាប់រងសុខភាពភាគច្រើន។ ប្រសិនបើអ្នកមិនមានធានារ៉ាប់រងសុខភាពទេ កូនរបស់អ្នកនៅតែអាចចាក់វ៉ាក់សាំងបានដូចគ្នា។ កម្មវិធីវ៉ាក់សាំងសម្រាប់កុមារ (VFC) ផ្តល់ជូនវ៉ាក់សាំងឥតគិតថ្លៃដល់កុមារអាយុដល់ទៅ 18 ឆ្នាំ ដែលមិនមានការធានារ៉ាប់រង ឬការធានារ៉ាប់រងរបស់គេមិនគ្របដណ្តប់តម្លៃរបស់វ៉ាក់សាំងនោះ។

ចូរសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ឬនាយកដ្ឋានសុខាភិបាលក្នុងតំបន់អំពីកម្មវិធី VFC។ រកគ្រូពេទ្យដែលចូលរួមក្នុងកម្មវិធី VFC នៅក្នុងតំបន់របស់អ្នក។

សម្រាប់ព័ត៌មានបន្ថែមអំពី HPV វ៉ាក់សាំង និងការបង្ការជំងឺមហារីក សូមទៅកាន់ មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ (Centers for Disease Control and Prevention)។